# PRESS RELEASE:

# Mekong Center Launches SCAMCHECK AI – Intelligent Scam Detection for Everyone

**PHNOM PENH, [December 06, 2025]** – The Mekong Center for Data Protection (MCDP) today announced the launch of **SCAMCHECK AI** , an intelligent, web-based tool designed to combat the rising tide of online scams and fraud across Cambodia and Southeast Asia.

SCAMCHECK AI provides instant scam detection to help everyday users protect themselves from online fraud.

### Addressing a Critical Regional Problem

The launch of SCAMCHECK AI comes as online scams pose a significant threat, with Cambodians alone losing an estimated $40 million to online fraud in the first half of 2024. Victims of these scams—including job scams, investment scams, and phishing messages—suffer significant financial losses and psychological distress.

SCAMCHECK AI directly addresses this critical issue as part of the Mekong Center for Data Protection's goals to:

- Reduce online scams and frauds in Cambodia and the region.
- Build national and regional awareness of digital literacy.
- Promote a safer digital ecosystem.

### How SCAMCHECK AI Works

SCAMCHECK AI is a simple, mobile-friendly application that leverages Artificial Intelligence to analyze suspicious content. Users can input text, photos, or URLs into the tool for immediate analysis.

The AI's analysis is based on multiple techniques, including:

- **Linguistic & Behavioral Forensics:** Detecting urgency, coercion patterns, and dialect mismatches.
- **Computer Vision & OCR:** Extracting text from images and detecting visual anomalies like forged logos.
- **Heuristic Analysis & Reputation Cross-Referencing:** Checking against scam databases for homograph attacks and assessing domain authority.

The tool then provides a clear output:

- A **Risk Level** (High Risk, Suspicious, or Low Risk).
- **Action Guidance** (e.g., "Do not click on the link," "Do not send money").
- An **Explanation** in plain language.

The application is initially available in Khmer and English, with plans for more languages in the future. Crucially, the MCDP assures users that all information provided for analysis will not be collected or stored.

**Who Can Benefit**

SCAMCHECK AI is designed for everyone:

- General public
- Online shoppers
- Job seekers
- Company staff and government employees
- Schools and NGOs providing digital safety training

**Future Vision**

Over the next six months, the MCDP plans to launch a Telegram group for crowdsourcing scam reports and building an automatic complaint tool to help victims report scams to authorities. Within 12-24 months, the tool is slated for expansion with multiple language support and a launch in neighboring countries.

**SCAMCHECK AI is now available to the public at www.scamcheck.online**.

**About the Mekong Center for Data Protection: MCDP** is a regional NGO focusing on research, policy and capacity building on data protection, privacy, and responsible data governance. We provide tools and resources to empower our partners to adopt the best data protection practices and comply with national and international regulations.

**Contact:**

- Website: www.mekongdataprotection.org
- Email: hello@mekongdataprotection.org

# សេចក្តីប្រកាសព័ត៌មាន៖

## មជ្ឈមណ្ឌលមេគង្គដាក់ឱ្យដំណើរការ SCAMCHECK AI – បច្ចេកវិទ្យា AI ឆ្លាតវៃសម្រាប់រាវរកការឆបោកសម្រាប់មនុស្សគ្រប់គ្នា

**ភ្នំពេញ, [ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០២៥]** – មជ្ឈមណ្ឌលមេគង្គសម្រាប់កិច្ចការពារទិន្នន័យ (Mekong Center for Data Protection – MCDP) បានប្រកាសដាក់ឱ្យដំណើរការ **SCAMCHECK AI** ដែលជាឧបករណ៍ AI ឆ្លាតវៃ ដែលត្រូវបានបង្កើតឡើងដើម្បីប្រយុទ្ធប្រឆាំងនឹងការកើនឡើងនៃការឆបោក និងការក្លែងបន្លំតាមអ៊ីនធឺណិតទូទាំងប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍ ។

SCAMCHECK AI ផ្តល់ជូនការវិភាគរកការឆបោកភ្លាមៗ ដើម្បីជួយអ្នកប្រើប្រាស់ទូទៅការពារខ្លួនពីការក្លែងបន្លំតាមអ៊ីនធឺណិត ។

## ដោះស្រាយបញ្ហាតំបន់ដ៏សំខាន់

ការដាក់ឱ្យដំណើរការ SCAMCHECK AI កើតឡើងស្របពេលដែលការឆបោកតាមអ៊ីនធឺណិតបង្កជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ក្នុងឆមាសទី ១ ឆ្នាំ ២០២៤ ប្រជាជនកម្ពុជាបានបាត់បង់ទឹកប្រាក់ប្រម៉ាន **៤០ លានដុល្លារ** ដោយសារការឆបោកតាមអ៊ីនធឺណិត ដែលរួមមានការឆបោកការងារ ការឆបោកវិនិយោគ និងសារបោកប្រាស់ផ្សេងទៀត ។ ជនរងគ្រោះនៃការឆបោកទាំងនេះមិនត្រឹមតែទទួលរងនូវការខាតបង់ផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់សុខភាពផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ។

SCAMCHECK AI មានគោលដៅជួយដោះស្រាយបញ្ហាសំខាន់នេះនិងមានគោលបំណង:

- កាត់បន្ថយការឆបោក និងការក្លែងបន្លំតាមអ៊ីនធឺណិតនៅកម្ពុជា និងក្នុងតំបន់
- កសាងការយល់ដឹងថ្នាក់ជាតិ និងតំបន់អំពីអក្ខរកម្មឌីជីថល
- លើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីឌីជីថលដែលកាន់តែមានសុវត្ថិភាព

## របៀបដែល SCAMCHECK AI ដំណើរការ

SCAMCHECK AI គឺជាកម្មវិធីងាយស្រួលប្រើលើទូរសព្ទ ដែលប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) ដើម្បីវិភាគខ្លឹមសារដែលគួរឱ្យសង្ស័យ ។ អ្នកប្រើប្រាស់អាចបញ្ចូលអត្ថបទ រូបថត ឬតំណភ្ជាប់ (URL) ទៅក្នុងឧបករណ៍នេះសម្រាប់ការវិភាគភ្លាមៗ ។

ការវិភាគរបស់ AI គឺផ្អែកលើបច្ចេកទេសជាច្រើន រួមមាន:

- **ការវិភាគកោសល្យវិច្ច័យភាសា និងអាកប្បកិរិយា** (Linguistic & Behavioral Forensics):
- **ចក្ខុវិស័យកុំព្យូទ័រ និងការសម្គាល់តួអក្សរអុបទិក** (Computer Vision & OCR):
- **ការវិភាគ Heuristic និងការផ្ទៀងផ្ទាត់កេរ្តិ៍ឈ្មោះ** (Heuristic Analysis & Reputation Cross-Referencing):

បន្ទាប់មក ឧបករណ៍នេះផ្តល់លទ្ធផលច្បាស់លាស់៖

- **កម្រិតហានិភ័យ (Risk Level):** ហានិភ័យខ្ពស់ (High Risk), គួរឱ្យសង្ស័យ (Suspicious), ឬហានិភ័យទាប (Low Risk)
- **ការណែនាំ (Action Guidance):** (ឧទាហរណ៍ "កុំចុចលើតំណភ្ជាប់," "កុំផ្ញើប្រាក់")
- **ការពន្យល់** ដោយប្រើភាសាសាមញ្ញ

បច្ចុប្បន្ន កម្មវិធីនេះអាចប្រើបានជាភាសាខ្មែរ និងអង់គ្លេស។ មជ្ឈមណ្ឌលមេគង្គក៏មានផែនការរួមបញ្ចូលភាសាជាច្រើនទៀតនៅពេលអនាគត ។ មជ្ឈមណ្ឌលបានធានាចំពោះអ្នកប្រើប្រាស់ថា ព័ត៌មានទាំងអស់ដែលផ្តល់សម្រាប់ការវិភាគ នឹងមិនត្រូវបានប្រមូល ឬរក្សាទុកឡើយ ។

## អ្នកណាខ្លះអាចទទួលបានអត្ថប្រយោជន៍

SCAMCHECK AI ត្រូវបានបង្កើតឡើងសម្រាប់មនុស្សគ្រប់គ្នា៖

- សាធារណជនទូទៅ
- អ្នកទិញទំនិញតាមអ៊ីនធឺណិត
- អ្នកស្វែងរកការងារ
- បុគ្គលិកក្រុមហ៊ុន និងមន្ត្រីរាជការ
- សាលារៀន និងអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ការបណ្តុះបណ្តាលសុវត្ថិភាពឌីជីថល

## ចក្ខុវិស័យអនាគត

ក្នុងរយៈពេលប្រាំមួយខែខាងមុខ MCDP គ្រោងនឹងបង្កើតក្រុម Telegram ដើម្បីប្រមូលរបាយការណ៍ឆបោកពីមហាជន និងបង្កើតឧបករណ៍ដាក់ពាក្យបណ្តឹងដោយស្វ័យប្រវត្តិដើម្បីជួយជនរងគ្រោះរាយ

ករណីការឆបោកទៅអាជ្ញាធរ ។ ក្នុងរយៈពេល ១២-២៤ ខែ ឧបករណ៍នេះនិងត្រូវបានគ្រោងដាក់ឱ្យដំណើរការនៅក្នុងប្រទេសជិតខាងផងដែរ ។

សាធារណជនអាចប្រើប្រាស់ SCAMCHECK AI នៅគេហទំព័រ **www.scamcheck.online** ។

**អំពីមជ្ឈមណ្ឌលមេគង្គសម្រាប់កិច្ចការពារទិន្នន័យ (MCDP):** MCDP គឺជាមជ្ឈមណ្ឌលក្នុងតំបន់សម្រាប់ការស្រាវជ្រាវ គោលនយោបាយ និងការពង្រឹងសមត្ថភាពលើកិច្ចការពារទិន្នន័យ ឯកជនភាព និងអភិបាលកិច្ចទិន្នន័យប្រកបដោយការទទួលខុសត្រូវ។ យើងផ្តល់ការកសាងសមត្ថភាព ឧបករណ៍ឌីជីថល និងចំណេះដឹង ដើម្បីឱ្យក្រុមហ៊ុន និងស្ថាប័នដែលជាដៃគូរ អនុវត្តកិច្ចការពារទិន្នន័យល្អបំផុត និងអនុលោមតាមបទប្បញ្ញត្តិជាតិ និងអន្តរជាតិ។

**ទំនាក់ទំនង:**


- Website: www.mekongdataprotection.org
- Email: hello@mekongdataprotection.org